សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣៩៧

ចុះថ្ងៃទី ២៤-០៨-២០០១

សាលដីកា

លេខ : ៤៨ "ច"

ចុះថ្ងៃទី ១០-០៩-២០០៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ : ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធាន |
| លោក | [redacted] | ចៅក្រមប្រឹក្សា |
| លោក | [redacted] | ចៅក្រមប្រឹក្សា |

**តំណាងមហាអយ្យការ**

| | | |
|---|---|---|
| លោក | [redacted] | ជាព្រះរាជអាជ្ញា |

**ក្រឡាបញ្ជី**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ : ៣៩៧ ចុះថ្ងៃទី២៤-០៨-២០០១ រវាង៖

-ជនជាប់ចោទឈ្មោះ [redacted] ឃឿន ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរកម្មកររើសែង ។ ទីកន្លែងកំណើតនៅភូមិស្វូទិព ឃុំស្វូទិព ស្រុកជើងព្រៃ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០១ នាក់ ។ ចាប់ខ្លួនថ្ងៃទី២៦.០៩.២០០០ មានមេធាវីការពារឈ្មោះ [redacted] ចន្ថា ។

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរគួកជេររថយន្ត ។ កើតនៅភូមិបឹងទំពុន សង្កាត់ត្នោតជុំ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ទីលំនៅសព្វថ្ងៃភូមិ [redacted] ។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូនបីនាក់ ។ ចាប់ខ្លួនថ្ងៃទី២៦.០៩.២០០០ មានមេធាវីការពារឈ្មោះ [redacted] ចន្ថា ។

-ជនជាប់ចោទឈ្មោះ [redacted] អឿន ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ របររកស៊ីជាងជួសជុលម៉ូតូ ។ កើតនៅភូមិកោះក្របី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឃុំ [redacted] ។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted]



Scanned with CamScanner

"ស" ។ ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ។ ចាប់ខ្លួនថ្ងៃទី២៦.០៩.២០០០ ។ មានមេធាវីការពារឈ្មោះ [redacted] ចន្ថា ។

-ជនជាប់ចោទឈ្មោះ [redacted] ផៃ ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីលំនៅសព្វថ្ងៃនៅភូមិគោកអំពិល ឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូនពីរនាក់ ។ ចាប់ខ្លួនថ្ងៃទី០៧.១០.២០០០ ។ មានមេធាវីការពារឈ្មោះ [redacted] ចន្ថា ។

<u>ជាប់ចោទពីបទ</u> : ក្រុមជនប្រដាប់អាវុធ និងពង្រត់មនុស្ស ក្នុងគោលដៅធ្វើវិច្ឆេទកម្មទារយកប្រាក់ ប្រព្រឹត្តនៅភូមិព្រះស្រែ ឃុំអន្លង់វិល ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៩ តាមមាត្រា៣៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងច្បាប់ស្ដីពីអំពីអាវុធកម្ម ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៤៥ឆ្នាំ មានទីលំនៅ [redacted] ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ ។ មានទីលំនៅ [redacted] ។

<u>ឯរឿងហេតុមានដូចតទៅ</u> ៖

កាលពីថ្ងៃទី២០.១០.១៩៩៩ ជនជាប់ចោទឈ្មោះ [redacted] ផៃ, [redacted] ឃឿន, [redacted] អឿន, [redacted] សុវណ្ណ និងបក្សពួកម្នាក់ឈ្មោះ [redacted] ជាធំ គ្មានសារេគា បានរួបរួមគ្នាជាក្រុមមានអាវុធអាកាបួនដើម និងកាំភ្លើងខ្លីមួយដើម ត្រៀមបំរុងទុកជាមុន ហើយធ្វើសកម្មភាពចាប់ជនរងគ្រោះឈ្មោះ [redacted] ទាពីរ នៅចំនុចភូមិព្រះស្រែ បង្ខំទារយកប្រាក់ ដោយទំនាក់ទំនងតាមវិទ្យុទាក់ទងមកគ្រួសារជនរងគ្រោះបានចំនួន១៧,០០០ដុល្លារសហរដ្ឋអាមេរិក( មួយម៉ឺនប្រាំពីរពាន់ដុល្លារសហរដ្ឋអាមេរិក) ទើបដោះលែងជនរងគ្រោះវិញ ហើយយកប្រាក់ចែកគ្នា ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ: ២៧ "គ" ចុះថ្ងៃទី០៥-០៤-២០០១ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ក.ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ផៃ ភេទប្រុស អាយុ៤១ឆ្នាំ ដាក់ពន្ធនាគារកំណត់០៤ឆ្នាំ ពីបទ: ក្រុមជនប្រដាប់អាវុធ និងដាក់ពន្ធនាគារកំណត់១២ឆ្នាំ ពីបទ: ពង្រត់មនុស្សក្នុងគោលដៅធ្វើវិច្ឆេទកម្មទារយកប្រាក់សរុបទោសគុកចំនួន១៦ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០០ ។

ខ.ផ្ដន្ទាទោសលើឈ្មោះ [redacted] ឃឿន ហៅ ធី ភេទប្រុស អាយុ៣៩ឆ្នាំ, [redacted] សុវណ្ណ ភេទប្រុស អាយុ៣៥ឆ្នាំ និង [redacted] អឿន ភេទប្រុស អាយុ៣២ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់១២ឆ្នាំ ពីបទ: ពង្រត់មនុស្សក្នុងគោលដៅធ្វើវិច្ឆេទកម្មទារយកប្រាក់ សរុបទោសគុកក្នុងម្នាក់ៗចំនួន១៦ឆ្នាំ បូកពីទណ្ឌកម្មនៃអំណាចសាលក្រមព្រហ្មទណ្ឌលេខ:២៦ "ឃ" ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០១ ។ ពីបទ: ក្រុមជនប្រដាប់អាវុធ និងបទ: ពង្រត់មនុស្សក្នុងគោលដៅធ្វើវិច្ឆេទកម្មទារយកប្រាក់ ប្រព្រឹត្តនៅភូមិព្រះស្រែ ឃុំអន្លង់វិល



១៣៥

Scanned with CamScanner

ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៩ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ និងមាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ។

២-វិទ្យុទាក់ទងធុនធំចំនួនមួយគ្រឿង ម៉ាកខេវ៉ែត ពណ៌ខ្មៅ លេខ៩០១០១៨៦៣ ប្រគល់ឱ្យឈ្មោះ [redacted] ទាតីវ ជាម្ចាស់ដើមវិញ ។

៣-ឱ្យឈ្មោះ [redacted]ផៃ, [redacted] ឃឿន, [redacted] ឃឿន និង [redacted] សុវណ្ណ រួបរួមគ្នាសងទៅឈ្មោះ [redacted] ទាតីវ ជាដើមបណ្តឹងនូវសំណងអន្តរាយ និងជម្ងឺចិត្តសរុបគិតជាប្រាក់រៀលស្មើនឹងតម្លៃប្រាក់អាមេរិកចំនួន២០.០០០ ដុល្លារសហរដ្ឋអាមេរិក (ម្ភៃពាន់ដុល្លារសហរដ្ឋអាមេរិក) ។ ដើមបណ្តឹងទាមទារលើសពីនេះបដិសេធចោល ។ ក្នុងករណីទាំងបួននាក់ខាងលើ គ្មានប្រាក់សងគ្រប់ទេ ត្រូវដាក់គុកបង្ខំរូបកាយក្នុងម្នាក់ៗ ចំនួន០២ (ពីរ) ឆ្នាំ ដើម្បីទារប្រាក់ធនទណ្ឌ ។ តាមមាត្រា០៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:១៨ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩២ ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹង ។

ទុករយៈពេលប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦.០៤.២០០១ របស់ឈ្មោះ [redacted] សុវណ្ណ, [redacted] អឿន, [redacted] ឃឿន និង [redacted] ផៃ ប្តឹងមិនសុខចិត្តនឹងសាលក្រមទាំងមូល ។

បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី ១២-០៣-២០០៣ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

- ប្រធានក្រុមប្រឹក្សាសង្ខេបធ្វើការអធិប្បាយសង្ខេបរឿង និងអានការសម្រេចសេចក្តីរបស់សាលាដំបូងខេត្តបាត់ដំបង ។

- តំណាងមហាអយ្យការសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ឃើញថា ត្រឹមត្រូវហើយ ជនជាប់ចោទបានឆ្លើយសារភាពហើយដែរ ដូច្នេះស្នើសុំតម្កល់សាលក្រមរបស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ចំពោះការប្រព្រឹត្តរបស់កូនក្តីខ្លួន ឃើញថា បានប្រព្រឹត្តជាច្រើនលើក [redacted] សូ អឿន មិនបានចូលរួមទេ ហើយក៏មិនបានស្គាល់អ្នកទាំងនោះដែរ ។ សូមក្រុមប្រឹក្សាលើកលែងការចោទប្រកាន់ដល់គាត់ផង ឯ [redacted] ផៃ មិនបានចូលរួមប្រព្រឹត្តទេ តែបានទទួលលុយពី ផាន់ និង ឃេត តែការប្រព្រឹត្ត [redacted] ផៃ ពុំដឹងការប្រព្រឹត្តរបស់គេទេ សុំក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់ឈ្មោះ [redacted] ផៃ ផងចុះ ។

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ





Scanned with CamScanner

...សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹង ។

ទុកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះចូលជាស្ថាពរចំពោះឈ្មោះ [redacted] ដៃ តែម្នាក់ប៉ុណ្ណោះ ក្រៅពីនេះពុំទាន់មានអានុភាពអនុវត្តនៅឡើយ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ០៦ ឆ្នាំ២០០៩

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]



Scanned with CamScanner

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យគ្រប់ឯកសារពាក់ព័ន្ធល្អិតល្អន់
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

**យល់ឃើញថា :**

១- ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦.០៤.២០០១ របស់ឈ្មោះ [redacted]សុវណ្ណ, [redacted]អឿន, [redacted] ឃឿន និង [redacted]ផៃ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ដោយយោងតាមមាត្រា១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] ឃឿន, [redacted] សុវណ្ណ, [redacted]អឿន និង[redacted] ផៃ បានឆ្លើយនៅសមត្ថកិច្ចកងរាជអាវុធហត្ថខេត្តបាត់ដំបង នៅអយ្យការអមតុលាការខេត្តបាត់ដំបង និងនៅចំពោះមុខចៅក្រមស៊ើបអង្កេតតុលាការខេត្តបាត់ដំបងថា ពួកខ្លួនពិតជាបានចាប់ជនរងគ្រោះឈ្មោះ [redacted] ទាពីរ ជំរិតទារប្រាក់ប្រាកដមែន ។ ហើយតាមភស្តុតាងនានា បានបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទទាំងបួននាក់នេះពិតជាបានចាប់ជនរងគ្រោះជំរិតទារប្រាក់ពិតមែន ។

៣- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]អឿន, [redacted]ឃឿន, [redacted]សុវណ្ណ និង ប៊ុន ផៃ ពីបទ: ក្រុមជនប្រដាប់អាវុធ និងភេរវកម្ម ប្រព្រឹត្តនៅភូមិព្រះស្រែ ឃុំអន្លង់វិល ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី២០.១០.១៩៩៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា០២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ។

៤-រឿងក្តីនេះតុលាការខេត្តបាត់ដំបង បានធ្វើការអង្កេត និងលើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូចនេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

៥- សាលក្រមព្រហ្មទណ្ឌលេខ:២៧ "គ" ចុះថ្ងៃទី០៤.០៤.២០០១ របស់តុលាការខេត្តបាត់ដំបង ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះ

## និច្ឆ័យសេចក្តី

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦.០៤.២០០១ របស់ឈ្មោះ [redacted]អឿន, [redacted] ឃឿន, [redacted] សុវណ្ណ និង [redacted]ផៃ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:២៧ "គ" ចុះថ្ងៃទី០៤.០៤.២០០១ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការដដែល ។

៣-សម្រេចឃុំខ្លួនឈ្មោះ [redacted]អឿន, [redacted] ឃឿន, [redacted] សុវណ្ណ និង [redacted] ផៃ នេះជាបន្ត។



Scanned with CamScanner